00729318

E62/3/10/5

**នៅចំពោះមុខ អង្គជំនុំជម្រះសាលាដំបូង**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អជដ
ភាគីដាក់ឯកសារ៖ សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី
ដាក់ជូន៖ អង្គជំនុំជម្រះសាលាដំបូង
ភាសាដើម៖ បារាំង(បកប្រែភាសាខ្មែរ)
កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១១

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 29 / 08 / 2011
ម៉ោង (Time/Heure): 10 : 20
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ៖ សាធារណៈ:
ចំណាត់ថ្នាក់ឯកសារដោយ កសចស៖ **សាធារណៈ / Public**
ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន៖
ឈ្មោះមន្ត្រីកត់ត្រា៖
ហត្ថលេខា៖

---

# សេចក្ដីសុំថ្លឹងសារនុក្រមរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីជំទាស់នឹងសេចក្ដីសម្រេចលេខ E62/3/10/4

---

**<u>ដាក់ដោយ៖</u>**

**សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ៖**
ពេជ អង្គ
Elisabeth SIMONNEAU-FORT

**សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី ៖**
គីម ម៉េងឃី
ម៉ុច សុវណ្ណារី
Evelyne BOILEAU-BRANDOMIR
Philippe CANONNE
Annie DELAHAIE
Laure DESFORGES
Ferdinand DJAMMEN NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Martine JACQUIN
Daniel LOSQ
Christine MARTINEAU
Barnabé NEKUIE
Elisabeth RABESANDRATANA
Fabienne TRUSSES NAPROUS
ស៊ីន សុវ៉ន

**<u>ដាក់ជូន៖</u>**

**អង្គជំនុំជម្រះសាលាដំបូង**
ចៅក្រម និល ណុន (ប្រធាន)
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម ធូ មណី

**<u>ចំលងជូន ៖</u>**

**អង្គជំនុំជម្រះតុលាការកំពូល៖**
ចៅក្រម **គង់ ស្រ៊ឹម (ប្រធាន)**
ចៅក្រម Motoo NOGUCHI
ចៅក្រម **សោម សិរីវឌ្ឍ**
ចៅក្រម Agnieszka KLONOWIECKA-MILART
ចៅក្រម **ស៊ិន រិទ្ធ**
ចៅក្រម Chandra Nihal Jayasinghe
ចៅក្រម **យ៉ា ណារិន**

សំ សុគង់

ទី ស្រ៊ីនណា

ហុង គឹមសួន

ជេត វណ្ណលី

ឡៃ ជុនធី

Emmanuel ALTIT
Pascal AUBOIN
Patrick BAUDOIN
Marie GUIRAUD
Evelyne BOILEAU-BRANDOMIR
Emmanuel JACOMY
Madhev MOHAN
Lyma Thuy NGUYEN
Julien RIVET
Nushin SARKARATI
Olivier BAHOUGNE
Philippine SUTZ

**សហព្រះរាជអាជ្ញា ៖**

ជា លាង

Andrew CAYLEY

**ជនជាប់ចោទ**

អៀង សារី

អៀង ធីរិទ្ធ

នួន ជា

**សហមេធាវីការពារក្ដីជនជាប់ចោទ**

អាង ឧត្ដម

Michael G.KARNAVAS

ផាត់ ពៅស៊ាង

Diana ELLIS

សុន អរុណ

Michiel PESTMAN
Victor KOPPE

**សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីផ្សេងទៀត**

Silke STUDZINSKY

វ៉ែន ពៅ

## I. សេចក្តីផ្តើម

1. ដោយអនុវត្តតាមវិធាន ១០៤ ១០៥ និង១០៦ នៃវិធានផ្ទៃក្នុង សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី សូមដាក់បណ្តឹងសារទុក្ខជំទាស់នឹងសេចក្តីសម្រេច[1] របស់អង្គជំនុំជម្រះសាលាដំបូង «អង្គជំនុំជម្រះ» កាលពីថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១១ E62/3/10/4 ដែលបានច្រានចោលការស្នើសុំអនុញ្ញាតនូវការមើលរបាយការណ៍វេជ្ជសាស្ត្ររបស់អ្នកជំនាញ John Campbell ដល់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់។

2. អនុលោមទៅនឹងវិធាន ១០៥(៣) វិធាន ១០៥(២) (ក) និង(ខ) វិធាន ១០៦ និង វិធាន ១០៧(៤)នៃវិធានផ្ទៃក្នុង«វិធាន» សហមេធាវីនាំមុខសូមដាក់ជូននូវសេចក្តីជូនដំណឹងអំពីបណ្តឹងសារទុក្ខ ដែលចង្អុលបង្ហាញនូវឆន្ទៈរបស់ខ្លួនដើម្បីជំទាស់នឹងសាលក្រម។

3. អនុវត្តទៅតាមវិធាន១០៤ (១)នៃវិធានផ្ទៃក្នុង សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីសូមលើកឡើងថា អង្គជំនុំជម្រះតុលាការកំពូលមានសមត្ថកិច្ចដើម្បីដោះស្រាយរាល់បញ្ហានៅក្នុង ក្រមខ័ណ្ឌនៃបណ្តឹងសារទុក្ខនេះ ហើយជាពិសេសសូមបង្ហាញថាអង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តនូវ៖

« a) ការភ័ន្តច្រឡំលើអង្គច្បាប់ដែលនាំឲ្យអសុពលភាពលើសេចក្តីសម្រេចខ្លួននេះ(...)»

## II. អំណះអំណាងបណ្តឹងសារទុក្ខ

4. ដោយអនុវត្តតាមវិធាន១០៥ (៣) នៃវិធានផ្ទៃក្នុង សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសូមលើកដូចខាងក្រោមនូវទឡ្ហីករណ៍សារទុក្ខដើម្បីឲ្យឃើញកាន់តែច្បាស់នូវរាល់ការភ័ន្តច្រឡំរបស់អង្គជំនុំជំម្រះសាលាដំបូងលើអង្គច្បាប់ដែលធ្វើឲ្យអសុពលភាពនូវសេចក្តីសម្រេច។

---

[1] E62/3/10/4 សេចក្តីសម្រេចលើ "សារណាបន្ទាន់ស្នើសុំអង្គជំនុំជម្រះសាលាដំបូងឲ្យកែតម្រូវអនុស្សរណៈ E62/3/10" (លេខឯកសារ E62/3/10/1)

**បណ្តឹងសារទុក្ខរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសំអាងលើអត្ថិភាពនៃការភ័ន្តច្រឡំអង្គច្បាប់ដែលនាំឱ្យអសុពលភាពសេចក្តីសម្រេចនេះ ។**

a) **ការភ័ន្តច្រឡំលើអង្គច្បាប់ពាក់ព័ន្ធនឹងកិច្ចការតំណាងផ្លូវច្បាប់ជូនដើមបណ្តឹងរដ្ឋប្បវេណី៖**

5. ការបកស្រាយ ស្តីអំពីការរៀបចំការតំណាងផ្លូវច្បាប់ដើម្បីដើមបណ្តឹងរដ្ឋប្បវេណី ដែលអង្គជំនុំជម្រះសាលាដំបូងបានចេញគឺ រំលោភបំពានលើវិធាន១២ស្ទួនពីរ វិធាន២១(១) និងវិធាន២៣(៣) នៃវិធានផ្ទៃក្នុង។

b) **ការភ័ន្តច្រឡំលើអង្គច្បាប់ពាក់ព័ន្ធនឹងការចូលមើលសំនុំរឿងរបស់គ្រប់មេធាវីទាំងអស់ដែលចូលធ្វើអន្តរាគមន៍ក្នុងនីតិវិធី ៖**

6. អង្គជំនុំជម្រះសាលាដំបូងបានធ្វើ មិនទទួលស្គាល់បទប្បញ្ញត្តិនៃវិធាន៨៦ វិធាន៤៦(១) វិធាន៣២ និងវិធាន២២(៣) នៃវិធានផ្ទៃក្នុង ដោយធ្វើការកំរិតការចូលមើលរបាយការណ៍របស់អ្នកជំនាញ ។

c) **ការភ័ន្តច្រឡំលើអង្គច្បាប់ពាក់ព័ន្ធនឹងការដាក់សារណានិងបណ្តឹងចំពោះមុខអង្គជំនុំជម្រះ ៖**

7. ដោយអនុលោមតាមវិធាន៨(៤)នៃសេចក្តីណែនាំអនុវត្ត ECCC01/2007 ស្តីពីការដាក់ឯកសារ វិសោធនកម្មលើកទី៦ សហមេធាវីមានសិទ្ធិឆ្លើយតបនឹងសារណា របស់ អៀង ធីរិទ្ធ[2] និង សារណារបស់ នួន ជា[3] ក្នុងរយៈពេលមួយ ប៉ុន្តែអង្គជំនុំជម្រះសាលាដំបូងមិនបានគោរពតាមកាលបរិច្ឆេទនេះទេ ។

---

[2] ឯកសារ E62/3/10/2 *ចម្លើយតបរបស់មេធាវីការពារក្តីអ្នកស្រី អៀង ធីរិទ្ធ ទៅនឹងសារណាបន្ទាន់របស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ស្នើសុំអង្គជំនុំជម្រះសាលាដំបូងឱ្យកែតម្រូវអនុស្សរណៈ E62/3/10 (អនុស្សរណៈចាស់ E106)* ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ ។

[3] ឯកសារ E62/3/10/3 *សេចក្តីជូនដំណឹងអំពីការចូលរួមជាមួយនឹងចម្លើយតបរបស់មេធាវីការពារក្តីលោកស្រី អៀង ធីរិទ្ធ ទៅនឹង "សំណើបន្ទាន់របស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំអង្គជំនុំជម្រះសាលាដំបូងកែតម្រូវអនុស្សរណៈ E62/3/10 (អនុស្សរណៈចាស់លេខ E106)* ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១១ ។

d) ការភ័ន្តច្រឡំលើអង្គច្បាប់របស់អង្គជំនុំជម្រះដែលនាំអោយប៉ះពាល់ដល់សិទ្ធិដើមបណ្តឹងរដ្ឋប្បវេណី៖

8. ការមិនផ្តល់ជូននូវរបាយការកោសល្យវិច្ច័យរបស់អ្នកជំនាញនោះដល់ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីដោយ អង្គជំនុំជម្រះសាលាដំបូង ធ្វើឲ្យប៉ះពាល់ដល់ សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដោយទាញចេញពីសិទ្ធិ របស់ជនរងគ្រោះ ដែលមានជាអាទិក្នុង វិធាន២១(១)(ក) និង(គ) នៃវិធានផ្ទៃក្នុង និងផ្ទុយទៅនឹង គោលការណ៍មូលដ្ឋាននានាដែលបានលើកឡើងក្នុងមហាសន្និបាត អង្គការសហប្រជាជាតិចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៥ [4]។

III. **សេចក្តីសន្និដ្ឋាន ÷**

9. សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីនឹងដាក់នូវសារណាគាំទ្រការស្នើសុំនោះ ក្នុងរយៈពេល ៦០ថ្ងៃ បន្ទាប់ អំពីការជូនដំណឹងនៃសេចក្តីជូនដំណឹងអំពីបណ្តឹងសារទុក្ខនេះ ។

10. សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំ៖

- ឲ្យប្រកាសថាអាចទទួលយកបាននូវបណ្តឹងឧទ្ធរណ៍ ។
- ឲ្យអនុញ្ញាតឲ្យចូលមើលឯកសារបន្ថែមនានា ។
- ឲ្យប្រកាសទុកជាមោឃៈសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្របតាមបទប្បញ្ញត្តិដែល បានលើកឡើងខាងលើ ។

---

[4] សូមមើល សេចក្តីសម្រេចមហាសន្និបាតអង្គការសហប្រជាជាតិ A/RES/60/147 ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ ២០០៦ ស្តីពី "គោលការណ៍ជាមូលដ្ឋាន និងគោលការណ៍ណែនាំស្តីពីសិទ្ធិទទួលបានការដោះស្រាយ និងការជួសជុលសំណង ព្យសនកម្មដល់ជនរងគ្រោះដោយសារការរំលោភបំពាលដ៏កម្រោលលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងការរំលោភបំពានដ៏ធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ"។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ២៥ សីហា ២០១១ | ពេជ អង្គ<br>**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី** | ភ្នំពេញ | |
| ២៥ សីហា ២០១១ | Elisabeth SIMONNEAU-FORT<br>**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី** | ភ្នំពេញ | |
| ២៥ សីហា ២០១១ | **ម៉ុច សុវណ្ណារី**<br>សហមេធាវីជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី | ភ្នំពេញ | |
| ២៥ សីហា ២០១១ | **គឹម ម៉េងឃី**<br>សហមេធាវីជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី | ភ្នំពេញ | |
| ២៥ សីហា ២០១១ | **Françoise GAUTRY**<br>សហមេធាវីអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី | ភ្នំពេញ | |